ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីក្រុងឡុងដ៏ នៃចក្រភពអង់គ្លេស ថ្ងៃចន្ទ ដល់ ពុធ ០១ ដល់ ០៣រោច ខែមិគសិរ ឆ្នាំរកា ព.ស. ២៥៦១
ត្រូវនឹងថ្ងៃទី០៤ ដល់ ០៦ ខែធ្នូ គ.ស. ២០១៧

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពី

# ដំណើរទស្សនកិច្ចសិក្សា អំពីយន្តការសម្រាប់រដ្ឋបាលសារពើពន្ធក្នុងការស៊ើបអង្កេតបទល្មើសពន្ធដារ និង ប្រយុទ្ធប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ

កាលពីថ្ងៃចន្ទ ដល់ ពុធ ០១ ដល់ ០៣រោច ខែមិគសិរ ឆ្នាំរកា ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី០៤ ដល់ ០៦ ខែធ្នូ គ.ស. ២០១៧ ឯកឧត្តមបណ្ឌិត **កែន សម្បត្តិ** អគ្គនាយករង នៃអគ្គនាយកដ្ឋានពន្ធដារ និងជាប្រធានក្រុមការងារសហប្រតិបត្តិការជាមួយ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា សម្រាប់ការវាយតម្លៃអញ្ញមញ្ញអំពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម បានដឹកនាំគណៈប្រតិភូ នៃអគ្គនាយកដ្ឋានពន្ធដារ រួមមានលោក **ចែម ខាសនា** នាយកសាលាជាតិពន្ធដារ និងជាអនុប្រធានក្រុមការងារ, លោក **ស្រ៊ុន អង្គរ៉េន** ប្រធាននាយកដ្ឋានស៊ើបអង្កេត បទល្មើសពន្ធដារ, លោក **ជ័យ រិទ្ធី** អនុប្រធាននាយកដ្ឋានច្បាប់វិវាទ និងស្ថិតិរួមទាំងមន្ត្រីជាន់ខ្ពស់នៃនាយកដ្ឋានពាក់ព័ន្ធ បំពេញទស្សនកិច្ចសិក្សានៅរដ្ឋបាលសារពើពន្ធនៅទីក្រុងឡុងដ៏ នៃចក្រភពអង់គ្លេស តបតាមការអញ្ជើញរបស់រដ្ឋបាលសារពើរពន្ធ នៃចក្រភពអង់គ្លេស (HM Revenue and Customs) និងតាមការចាត់តាំងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងអគ្គនាយកដ្ឋានពន្ធដារ។

ដំណើរទស្សនកិច្ចសិក្សានេះ ត្រូវបានរៀបចំឡើងជាសំខាន់ ដើម្បីពិភាក្សានិងចែករំលែកបទពិសោធន៍ អំពីយន្តការសម្រាប់រដ្ឋបាលសារពើពន្ធក្នុងការ ស៊ើបអង្កេតបទល្មើសពន្ធដារ និង ប្រយុទ្ធប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ជាពិសេស ដើម្បីស្វែងយល់អំពីក្របខ័ណ្ឌច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធក៏ដូចជាវិធានការនានា ដែលរដ្ឋបាលសារពើពន្ធរបស់



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ

ប្រទេសទាំងពីរកំពុងអនុវត្តនៅក្នុងក្របខ័ណ្ឌ នៃការប្រយុទ្ធប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ។

បន្ទាប់ពីលោក Simon Grunwell នាយករងនៃសេវាកម្មស៊ើបអង្កេតបទល្មើសសារពើពន្ធនៃ រដ្ឋបាលសារពើពន្ធនៃចក្រភពអង់គ្លេសបានសំដែង នូវការស្វាគមន៍យ៉ាងកក់ក្តៅរួចមករដ្ឋបាលសារពើពន្ធនៃចក្រភពអង់គ្លេស បានធ្វើការចែករំលែកបទពិសោធន៍របស់ខ្លួនជូនគណៈប្រតិភូ របស់អគ្គនាយកដ្ឋានពន្ធដារ តាមរយៈការធ្វើបទបង្ហាញ និងកិច្ចពិភាក្សារបស់ខ្លួនជាមួយមន្ត្រីជាន់ខ្ពស់ និងមន្ត្រីជំនាញពាក់ព័ន្ធដោយផ្តោតលើប្រធានបទដូចខាងក្រោម៖

- ហានិភ័យនៃការសម្អាតប្រាក់នៅចក្រភពអង់គ្លេស និងយុទ្ធសាស្ត្ររបស់ចក្រភពអង់គ្លេស ក្នុងការបង្ក្រាបបទល្មើសនិងប្រយុទ្ធប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម
- ក្របខ័ណ្ឌច្បាប់នៃការប្រយុទ្ធប្រឆាំងការសម្អាតប្រាក់ និងដែនសមត្ថកិច្ចរបស់រដ្ឋបាលសារពើពន្ធនៃចក្រភពអង់គ្លេស
- ការអនុវត្តច្បាប់ស្តីពីបទល្មើសហិរញ្ញវត្ថុ
- ការប្រើប្រាស់ប្រព័ន្ធគាំទ្រតាមអេឡិកត្រូនិកក្នុងការប្រឆាំងការសម្អាតប្រាក់
- ប្រព័ន្ធនៃការស៊ើបការណ៍ហិរញ្ញវត្ថុរបស់ចក្រភពអង់គ្លេស
- ការគ្រប់គ្រងលើអ្នកធ្វើអាជីវកម្មសេវាកម្មប្រាក់ (Money Service Business)
- ការចូលរួមរបស់រដ្ឋបាលសារពើពន្ធនៃចក្រភពអង់គ្លេសជាមួយភ្នាក់ងារជាតិប្រឆាំងបទឧក្រិដ្ឋ (National Crime Agency) និងក្រុមការងារចម្រុះស៊ើបការណ៍ការសម្អាតប្រាក់ (JMLIT)
- ការបង្ក្រាបរបស់រដ្ឋបាលសារពើពន្ធនៃចក្រភពអង់គ្លេសទៅលើជនសមគំនិតនៃបទល្មើសសម្អាតប្រាក់
- ការចុះបញ្ជីនិងការគ្រប់គ្រងបរធនបាលកិច្ច (Trust) និងអ្នកទទួលផលចុងក្រោយ (Beneficial Ownership)
- កិច្ចសហប្រតិបត្តិការអន្តរជាតិ និងការផ្តល់ជំនួយផ្នែកច្បាប់ទៅវិញទៅមករវាងរដ្ឋបាលពន្ធដារ
- តួនាទីរបស់រដ្ឋបាលសារពើពន្ធនៃចក្រភពអង់គ្លេស ក្នុងឋានៈជាអាជ្ញាធរគ្រប់គ្រងលើការប្រឆាំងការសម្អាតប្រាក់ (Anti-Money Laundering Supervisor)
- ការស្វែងរកនិងការរឹបអូសផលនៃបទល្មើស។

ស្របពេលជាមួយគ្នានេះដែរ លោក ស្រ៊ុន អង្គរ៉េន ប្រធាននាយកដ្ឋានស៊ើបអង្កេតបទល្មើសពន្ធដារ ក៏បានឡើងធ្វើបទបង្ហាញ និងចែករំលែកពាក់ព័ន្ធទៅនឹងច្បាប់ និងបទប្បញ្ញត្តិ ក៏ដូចជាយន្តការ និងវិធានការនានារបស់ព្រះរាជាណាចក្រកម្ពុជា ក្នុងនោះក៏រួមមានអគ្គនាយកដ្ឋានពន្ធដារ នៅក្នុងការស៊ើបអង្កេតបទល្មើសពន្ធដារ និងការចូលរួមប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។ បន្ទាប់មក ឯកឧត្តមបណ្ឌិត កែន សម្បត្តិ អគ្គនាយករង នៃអគ្គនាយកដ្ឋានពន្ធដារ បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់រដ្ឋបាលសារពើពន្ធនៃចក្រភពអង់គ្លេស ដែលបានចំណាយពេលដ៏មានតម្លៃ ដើម្បីរៀបចំដំណើរទស្សនកិច្ចសិក្សាដ៏មានសារៈសំខាន់ សម្រាប់គណៈប្រតិភូនៃអគ្គនាយកដ្ឋានពន្ធដារ ដើម្បីចែករំលែកអំពីយន្តការ និងវិធានការនានាក្នុងការប្រយុទ្ធប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មនៅចក្រភពអង់គ្លេស និងការផ្តល់នូវធាតុចូលផ្សេងៗទៀត ក៏ដូចជាការចែករំលែកនូវបទពិសោធន៍ ចំណេះដឹង និងការអនុវត្តនៅក្នុងវិស័យសារពើពន្ធ។ ឯកឧត្តមបណ្ឌិតបានលើកឡើងថាការ



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ

បំពេញបេសកកម្ម របស់គណៈប្រតិភូអគ្គនាយកដ្ឋានពន្ធដារនេះ ពិតជាមានសារសំខាន់ណាស់ ក្នុងការស្រូបយកនូវពុទ្ធិ និងបទពិសោធន៍ថ្មីៗល្អៗ ទាំងក្នុងក្របខ័ណ្ឌបទប្បញ្ញត្តិច្បាប់ទាំងក្នុងក្របខ័ណ្ឌយន្តការ និងការអនុវត្តល្អជាអន្តរជាតិដើម្បីធ្វើជាធាតុចូលសម្រាប់ការពង្រឹង និងធ្វើឱ្យប្រសើរឡើងថែមទៀតក្នុងការចូលរួមប្រយុទ្ធប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម នៃសមត្ថកិច្ចរបស់អគ្គនាយកដ្ឋានពន្ធដារ និងជាការបង្ហាញពីកិច្ចសហប្រតិបត្តិការអន្តរជាតិ រវាងប្រទេសទាំងពីរផងដែរ។ ក្នុងនោះដែរ ឯកឧត្តមបណ្ឌិត បានបន្ថែមទៀតថា រដ្ឋាភិបាលនៃចក្រភពអង់គ្លេស គឺជាដៃគូអភិវឌ្ឍន៍ដ៏សំខាន់មួយ ដែលគាំទ្រដល់ការអភិវឌ្ឍនៅក្នុងប្រទេសកម្ពុជា ចាប់តាំងពីឆ្នាំ១៩៩២ និងមានកិច្ចសហប្រតិបត្តិការ ជាមួយព្រះរាជាណាចក្រកម្ពុជា ដោយផ្តោតភាគច្រើន ទៅលើវិស័យសង្គមកិច្ច (សុខាភិបាល និងអប់រំ) វិស័យអភិបាលកិច្ច និងការអភិវឌ្ឍជនបទ (ការទ្រទ្រង់ជីវភាពរស់នៅ) ។ លើសពីនេះទៅទៀត ចក្រភពអង់គ្លេស គឺជាដៃគូពាណិជ្ជកម្មដ៏សំខាន់ សម្រាប់ព្រះរាជាណាចក្រកម្ពុជា បើតាមស្ថិតិទទួលបានពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ចក្រភព-អង់គ្លេស គឺជាអ្នកវិនិយោគធំលំដាប់ទីពីរ នៅព្រះរាជាណាចក្រ-កម្ពុជា ក្នុងឆ្នាំ២០១៥។ ជាចុងក្រោយឯកឧត្តមបណ្ឌិត បានបន្តទៀតថា កម្ពុជាបានក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតទាបនិងត្រៀមប្រែក្លាយខ្លួនជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់ នៅឆ្នាំ២០៣០ និងជាប្រទេសដែលមានចំណូលខ្ពស់ ឬប្រទេសអភិវឌ្ឍន៍នៅឆ្នាំ២០៥០ ហើយគឺជាខ្លាសេដ្ឋកិច្ចថ្មីនៅអាស៊ី បើតាមការបញ្ជាក់ពីធនាគារអភិវឌ្ឍន៍ នេះក៏ដោយសារស្ថិតក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់ប្រកបដោយ គតិបណ្ឌិត និងវៃឈ្លាសរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាផងដែរ ដែលតែងតែរក្សាបាននៅសុខសន្តិភាព និងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។ សមិទ្ធផលដែលកម្ពុជាសម្រេចបាននាពេលនេះ មិនអាចកាត់ផ្តាច់បានពីដៃគូអភិវឌ្ឍន៍នានា រួមទាំងចក្រភពអង់គ្លេស។ ឯកឧត្តមបណ្ឌិត កែន សម្បត្តិ បានគូសបញ្ជាក់ថា សន្តិភាពនេះគឺជាបុរេលក្ខខណ្ឌ មិនអាចខ្វះបានសម្រាប់ការអភិវឌ្ឍលើគ្រប់វិស័យការវិនិយោគក៏ដូចជាធុរកិច្ចនានា នៅព្រះរាជាណាចក្រកម្ពុជា។

ជាចុងក្រោយ ឯកឧត្តមបណ្ឌិត កែន សម្បត្តិ បានបញ្ជាក់ថា នឹងយកចំណេះដឹង និងបទពិសោធន៍ថ្មីៗដែលបានពីដំណើរទស្សនកិច្ចសិក្សានេះ សម្រាប់ជាធាតុចូលក្នុងការរៀបចំគោលនយោបាយពន្ធដារឱ្យកាន់តែប្រសើរឡើង។ ទន្ទឹមនឹងនេះ ឯកឧត្តម និងក្រុមការងារក៏នឹងចែករំលែកនូវចំណេះដឹង និងបទពិសោធន៍ថ្មីទាំងនេះ ដល់សហការីរបស់ខ្លួន និងបង្កើនសមត្ថភាពការងាររបស់ស្ថាប័នឱ្យកាន់តែប្រសើរឡើងថែមទៀត។៚



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ




© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ